# គណនេយ្យភាពសង្គម ក្នុងមួយក្រឡេកភ្នែក

WGPD

Working Group for Partnerships in Decentralization
ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ

ខិត្តប័ណ្ណព័ត៌មានសម្រាប់សមាជិក

# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

**តើគណនេយ្យភាពគឺជាអ្វី?**

**ដើម្បីពន្យល់ទស្សនាទាននៃគណនេយ្យភាពសង្គម វាគឺជាប្រការសំខាន់ដែលគេត្រូវចាប់ផ្តើមដំបូងជាមួយនិយមន័យនៃពាក្យគណនេយ្យភាព។**

គណនេយ្យភាព គឺជាភាពឆ្លើយតប ភាពស្តីបន្ទោស ភាពទទួលខុសត្រូវ និង ការរំពឹងនៃការផ្តល់គណនេយ្យ ពោលគឺ ពន្យល់ និង ធ្វើយុត្តិកម្ម។

សមាជិកក្រុមប្រឹក្សា អភិបាល សមាជិកនៃគណៈអភិបាល និង មន្ត្រីរដ្ឋការ ជាទូទៅ ជនទាំងឡាយណាដែលទទួលខុសត្រូវលើការអនុវត្តធុរកិច្ចសាធារណៈ និង លើការចាយប្រាក់សាធារណៈ ត្រូវឆ្លើយតប និង ទទួលខុសត្រូវលើការធានាឲ្យបានប្រាកដថា ធុរកិច្ចសាធារណៈត្រូវបានបំពេញស្របតាមច្បាប់ និង ការប្រតិបត្តិសមស្រប។ ពួកគេត្រូវតែធានាឲ្យបានផងដែរថា ប្រាក់សាធារណៈត្រូវបានការពារ ត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ និង ត្រូវបានប្រើយ៉ាងសន្សំសំចៃ ប្រកបដោយប្រសិទ្ធផល និង ប្រសិទ្ធភាព។

គណនេយ្យភាព ធានាឲ្យបានថាសកម្មភាពនិងសេចក្តីសម្រេចទាំងឡាយដែលត្រូវបានធ្វើដោយមន្ត្រីសាធារណៈត្រូវស្ថិតក្រោមការត្រួតពិនិត្យ ដើម្បីធានាថាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលបំពេញតាមគោលដៅបញ្ជាក់របស់ខ្លួន និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ដែលខ្លួនសំដៅផ្តល់ផលប្រយោជន៍ ដែលជាហេតុរួមចំណែកដល់អភិបាលកិច្ចកាន់តែប្រសើរឡើង និង ការកាត់បន្ថយភាពក្រីក្រ។

គណនេយ្យភាព តម្រូវឲ្យមានលក្ខខណ្ឌបី: ១) តម្លាភាពនៅក្នុងទំនាក់ទំនងរវាងពលរដ្ឋ និង មន្ត្រីរដ្ឋាភិបាល, ២) ស្មារតីនៃកាតព្វកិច្ច និង គុណធម៌សេវាសាធារណៈ ក្នុងចំណោមមន្ត្រីរដ្ឋាភិបាលដែលត្រូវឆ្លើយតបចំពោះពលរដ្ឋ, និង ៣) អំណាចរបស់ពលរដ្ឋក្នុងការដាក់ទណ្ឌកម្ម ដាក់តម្លៃ ឬ ដកមន្ត្រីរដ្ឋាភិបាល ដោយសារស្នាដៃការងារឬអំពើមិនជាទីពេញចិត្ត។

យន្តការសំខាន់មួយនៃគណនេយ្យភាពនៅក្នុងរដ្ឋប្រកាន់លទ្ធិប្រជាធិបតេយ្យ គឺការបោះឆ្នោត។ ប៉ុន្តែការបោះឆ្នោតគឺជាឧបករណ៍ដ៏គ្រោតគ្រាតដែលត្រូវបានប្រើដើម្បីតម្រូវឲ្យរដ្ឋាភិបាលមានគណនេយ្យភាព។ ទោះបីជាពលរដ្ឋត្រូវបានផ្តល់ព័ត៌មានយ៉ាងពេញលេញ និង យ៉ាងត្រឹមត្រូវអំពីទស្សនៈ និង សកម្មភាពនានារបស់រាល់បេក្ខជននយោបាយ (ដែលពិតជាខុសពីករណីជាក់ស្តែង) ក្តី ក៏ការបោះ

ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ គឺជាសម្ព័ន្ធភាពសង្គមស៊ីវិលមួយដែលជំរុញវិមជ្ឈការនៅកម្ពុជា ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍបែបប្រជាធិបតេយ្យ



ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ គឺជាសម្ព័ន្ធភាពសង្គមស៊ីវិលមួយដែលបំពេញវិមជ្ឈការនៅកម្ពុជា ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍបែបប្រជាធិបតេយ្យ

**ខិត្តប័ណ្ណព័ត៌មានសម្រាប់សមាជិក**

# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

ឆ្នោតបានត្រឹមតែអនុញ្ញាតឲ្យពលរដ្ឋជ្រើសរើសក្នុងចំណោមបុគ្គលឬគណៈបក្សនយោបាយតែមួយចំនួនតូចប៉ុណ្ណោះ។ ការបោះឆ្នោតមិនផ្តល់ជូនពលរដ្ឋនូវឱកាសដើម្បីសម្តែងការចង់បានរបស់ពួកគេលើបញ្ហាជាក់លាក់ រួមចំណែកប្រកបដោយអត្ថន័យដល់ការធ្វើសេចក្តីសម្រេចចិត្តសាធារណៈ ឬ តម្រូវឲ្យតួអង្គសាធារណៈមានគណនេយ្យភាពចំពោះការសម្រេចចិត្ត ឬ ឥរិយាបថជាក់លាក់ឡើយ។

**តើគណនេយ្យភាពសង្គមគឺជាអ្វី?**

គណនេយ្យភាពសង្គម គឺជាអភិក្រមមួយឆ្ពោះទៅកាន់ការកសាងគណនេយ្យភាព ដែលផ្អែកលើការចូលរួមរបស់ពលរដ្ឋ ដែលនៅក្នុងនោះ ពលរដ្ឋនិងអង្គការសង្គមស៊ីវិលចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលក្នុងការទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវា និង មន្ត្រីសាធារណៈ។

គណនេយ្យភាពសង្គម រួមមានសកម្មភាពនិងយន្តការនានា (លើសពីការបោះឆ្នោត) ដែលពលរដ្ឋសហគមន៍ អង្គការសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ អាចប្រើបានដើម្បីតម្រូវឲ្យមន្ត្រីសាធារណៈ និង មន្ត្រីរដ្ឋការមានគណនេយ្យភាព និង ដើម្បីចាប់ផ្តើមការចូលរួមក្នុងលក្ខណៈស្ថាបនា។ សកម្មភាពផ្សេងៗមួយចំនួនដែលដឹកនាំដោយពលរដ្ឋ ឬ សង្គមស៊ីវិល គឺអាចធ្វើបាន ដូចជាការស្នើសុំឲ្យដាក់ប្រធានបទក្នុងរបៀបវារៈរបស់ក្រុមប្រឹក្សា ការនិយាយនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ការដាក់ញត្តិ យុទ្ធនាការតស៊ូមតិ បាតុកម្មសាធារណៈ ការតវ៉ា និង សារព័ត៌មានបែបស៊ើបអង្កេត។ មិនតែប៉ុណ្ណោះ សកម្មភាពដែលដឹកនាំដោយពលរដ្ឋ ឬ សង្គមស៊ីវិលក៏រាប់បញ្ចូលផងដែរការត្រួតពិនិត្យតាមដានស្នាដៃការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និង អ្នកផ្តល់សេវា នៅពេលដែលពួកគេធ្វើ អនុវត្ត និង ប្រតិបត្តិសេចក្តីសម្រេចសាធារណៈនានាទាក់ទិននឹងសិទ្ធិ បទប្បញ្ញត្តិ ការវិនិយោគ/ធនធានក្នុងមូលដ្ឋាន និង ការផ្តល់សេវា។

ឧបសគ្គពីរត្រូវតែជំនះឲ្យបានដើម្បីឲ្យការណ៍នេះកើតឡើងបាន: ពលរដ្ឋត្រូវតែមានព័ត៌មានដែលអាចទុកចិត្តបានអំពីសិទ្ធិទទួលរបស់ពួកគេ និង ស្នាដៃអនុវត្តនៃសេវាកម្ម ហើយពួកគេត្រូវតែអាចធ្វើសកម្មភាពដោយផ្អែកលើព័ត៌មាននោះដើម្បីទាមទារគណនេយ្យភាព ដែលគឺជាកិច្ចការដែលជាញឹកញាប់តម្រូវឲ្យមានសកម្មភាពជាសមូហភាព។

សមាសភាគសំខាន់ៗនៃកិច្ចដំណើរការនេះ រួមមាន៖

- ការត្រៀមលក្ខណៈក្រុមសហគមន៍ និង ក្រុមសង្គមស៊ីវិលដើម្បីចូលរួម — រួមមានការជំរុញការយល់ដឹងរបស់ពលរដ្ឋ ការកសាងទំនុកចិត្តនិងសមត្ថភាពសម្រាប់ការចូលរួម ការកសាងបណ្តាញ



# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

និងសម្ព័ន្ធភាព។

- ការប្រមូល ការវិភាគ និង ការប្រើព័ត៌មាន – រួមមានការរកបាន ការទទួលបាន និង ការវិភាគព័ត៌មានអំពីសកម្មភាពរដ្ឋាភិបាល ការប្រែក្លាយព័ត៌មានទៅជាទម្រង់ផ្សេងៗ និង ការចែករំលែកព័ត៌មានតាមរយៈកញ្ចប់ព័ត៌មាន និង តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង បណ្តាញសង្គម និងបណ្តាញនយោបាយ។
- ការធ្វើការចូលរួមគណនេយ្យភាពជាមួយរដ្ឋាភិបាល – រួមមានការប្រើឧបករណ៍នានា ដូចជា ប័ណ្ណដាក់ពិន្ទុ សវនកម្ម និង ការវិភាគថវិកា ដើម្បីចូលរួមជាមួយរដ្ឋាភិបាល ឬមួយដោយប្រើវិសាលភាពផ្លូវការមានស្រាប់សម្រាប់ការចូលរួមក្នុងការរៀបចំផែនការឬវដ្តគោលនយោបាយនានា ឬមួយដោយអភិវឌ្ឍវិសាលភាពថ្មីមួយ ឬមួយដោយធ្វើចលនាការតវ៉ាសង្គម។
- ការប្រើព័ត៌មានពីការចូលរួមគណនេយ្យភាពជាមួយរដ្ឋាភិបាល – រួមមានការតស៊ូមតិ ការបញ្ចុះបញ្ចូល (lobbying) និង ការងារយុទ្ធនាការដើម្បីតាមដានមើលការអនុវត្តការសន្យា។

**តើគណនេយ្យភាពសង្គមគប្បីដំណើរការយ៉ាងដូចម្តេចនៅកម្ពុជា?**

ក្នុងឆ្នាំ ២០១៣ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) បានធ្វើការជាមួយអង្គការសង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមមួយដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្រោយពេលអនុម័តផែនការយុទ្ធសាស្ត្រនេះ សង្គមស៊ីវិល និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានសហការគ្នាលើផែនការមួយសម្រាប់ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (I-SAF)។ ផែនការសម្រាប់ការអនុវត្តនេះ កំណត់វិសាលភាពនិងខ្លឹមសារនៃសកម្មភាពរួមដោយរាជរដ្ឋាភិបាល និង សង្គមស៊ីវិល ជុំវិញសកម្មភាពបី: (១) ការទទួលព័ត៌មាន, (២) ថវិកាមូលដ្ឋានបើកទូលាយ និង (៣) ការត្រួតពិនិត្យតាមដានដោយពលរដ្ឋ។ សកម្មភាពទាំងនេះ នឹងត្រូវបានអនុវត្តនៅក្នុងឃុំ មណ្ឌលសុខភាព និង សាលាបឋមសិក្សា។

(១) **តម្លាភាព ការទទួលព័ត៌មាន និង ថវិកាបើកទូលាយ** គឺជាសមាសភាគដ៏សំខាន់នៃប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គណនេយ្យភាពសង្គម។ បើគ្មានព័ត៌មានអំពីនិយាមនៃសេវាកម្ម ពលរដ្ឋមិនអាចដឹងថាតើត្រូវរំពឹងអ្វី ឬ ស្នើសុំអ្វីពីមណ្ឌលសុខភាព សាលារៀន ឬរដ្ឋបាលថ្នាក់ក្រោមជាតិទេ។ ក្រោយពេលដែលតួអង្គទាំងអស់ទទួលបានព័ត៌មានដូចគ្នា



# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

សក្តានុពលសម្រាប់ការយល់គ្នាកាន់តែប្រសើរឡើង ទំនាក់ទំនងកាន់តែល្អឡើង និង សកម្មភាពជាសមូហភាព ត្រូវបានលើកកម្ពស់យ៉ាងខ្លាំង។ ការសន្ទនាដែលផ្អែកលើទិន្នន័យ និងភស្តុតាង មានឱកាសកាន់តែច្រើនឡើងនៃការនាំទៅដល់ការកែលម្អជាក់ស្តែង។

(២) **ព័ត៌មានស្តីពីថវិកានិងចំណាយ** គឺជាកញ្ចប់រងដ៏សំខាន់មួយនៃព័ត៌មាន។ ការស្រាវជ្រាវបង្ហាញថា នៅកម្ពុជា ទាំំអតម្លាភាពហិរញ្ញវត្ថុសាធារណ: ទាំងការយល់ដឹងរបស់ពលរដ្ឋអំពីបញ្ហាហិរញ្ញវត្ថុសាធារណ: ចាំបាច់ត្រូវកែលម្អ។

**(៣) ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**

ដោយមានជំនួយពីអ្នកសម្របសម្រួលសហគមន៍ជំនាញផ្នែកគណនេយ្យភាព និង ដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និង ដោយមានព័ត៌មានអំពីនិយាមរដ្ឋាភិបាល និង សូចនាករស្នាដៃការងារ ក្រុមពលរដ្ឋ នឹង: (១) ធ្វើការវាយតម្លៃដោយខ្លួនឯងលើអ្នកផ្តល់សេវាមូលដ្ឋាន (រួមមាន មណ្ឌលសុខភាព សាលារៀន ឃុំ) និង (២) កំណត់លំដាប់អាទិភាពនៃកង្វល់ធំៗបំផុតរបស់ពួកគេ។

របកគំហើញនៃការវាយតម្លៃទាំងនេះដោយពលរដ្ឋ – ដែលឈ្មោះថាប័ណ្ណដាក់ពិន្ទុសហគមន៍ – ត្រូវបានចែករំលែកនិងពិភាក្សានៅពេលបន្ទាប់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ ក៏ដូចជាអ្នកផ្តល់សេវា និង មន្ត្រីស្រុកនានានៅក្នុងកិច្ចប្រជុំមួយដែលមានការសម្របសម្រួល ដែលមានឈ្មោះថាកិច្ចប្រជុំរួមគ្នាមួយ។ នៅក្នុងកិច្ចប្រជុំរួមគ្នានេះ កិច្ចប្រឹងប្រែងនឹងត្រូវបានធ្វើដើម្បីសម្រេចថាតើត្រូវធ្វើអ្វីខ្លះចំពោះបញ្ហាទាំងនោះ តាមរយៈកិច្ចដំណើរការមួយនៃការរៀបចំផែនការសកម្មភាព ដែលមានឈ្មោះថាផែនការសកម្មភាពគណនេយ្យភាពរួមគ្នា (JAAPs)។

**លទ្ធផល**

ការរៀបចំនិងការអនុវត្ត *ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម* ត្រូវបានរំពឹងថានឹងសម្រេចបានលទ្ធផលដូចខាងក្រោម៖

១. ការផ្លាស់ប្តូរមួយនៅក្នុង ឬ ចម្លើយមួយ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ជាលទ្ធផលនៃអន្តរកម្មរបស់ខ្លួនជាមួយពលរដ្ឋ និង/ឬ តំណាងពលរដ្ឋ។

២. សមត្ថភាពកែលម្អរបស់ពលរដ្ឋ (ស្ត្រី និង បុរស) និង អង្គការតំណាងពួកគេ ក្នុងការចូល



# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

រួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកស្ទួយគណនេយ្យភាពបែបប្រជាធិបតេយ្យ។

ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រស្ដីពីគណនេយ្យភាពសង្គមក៏រំពឹងថានឹងរួមចំណែកផងដែរដល់ផលប្រយោជន៍ដូចខាងក្រោម៖

៣. ការផ្ដល់សេវានិងការបែងចែកធនធានកាន់តែមានលក្ខណៈប្រកបដោយប្រសិទ្ធភាព សមធម៌ និង គណនេយ្យភាព។

៤. សហគមន៍ និង ពលរដ្ឋមូលដ្ឋាន ជាពិសេស ស្ត្រីនិងយុវជនជាតួអង្គសំខាន់រួមចំណែកដល់ការផ្លាស់ប្ដូរ កាន់តែមានអំណាចឡើង ជាក្រុមពលរដ្ឋ និង ក្រុមសម្ព័ន្ធភាព ដែលជួយឲ្យពួកគេអាចយល់ពីសិទ្ធិ និង ការទទួលខុសត្រូវរបស់ពួកគេ និង ចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

៥. ទុនសង្គមត្រូវបានលើកស្ទួយ ហើយទំនុកចិត្តរវាងសមាជិកសហគមន៍ និង រវាងពលរដ្ឋ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែលម្អ ដែលនឹងនាំទៅដល់សាមគ្គីភាពសង្គមកាន់តែរឹងមាំឡើង និង នឹងជំរុញទាំងការអភិវឌ្ឍសង្គម ទាំងកំណើនសេដ្ឋកិច្ច។

**តើមានអ្វីខ្លះត្រូវបានធ្វើរួចហើយមកដល់ពេលនេះ?**

- ការអភិវឌ្ឍកញ្ចប់ *ព័ត៌មានសម្រាប់ពលរដ្ឋ*។




ដើម្បីចាប់ផ្ដើមកិច្ចដំណើរការចែករំលែក និង ពិភាក្សាព័ត៌មាននៅថ្នាក់មូលដ្ឋាន ព័ត៌មានស្ដួលមួយឈុតទាក់ទិននឹងស្នាដៃការងាររបស់ឃុំ សាលារៀន និង មណ្ឌលសុខភាព គឺចាំបាច់។ ផ្ទាំងព័ត៌មាន ត្រូវបានរៀបចំជាមួយព័ត៌មានអំពីសិទ្ធិ និយាម និង ចំណុចដៅនានា។ នៅលើផ្ទាំងព័តមាន លំហាទំនេរត្រូវបានទុកចំហរ



# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

សម្រាប់បិទក្រដាសទំហំ A៤ ដែលមានស្នាដៃការងារ ថវិកា និង ចំណាយ។ តាមមធ្យោបាយនេះ ផ្ទាំងព័ត៌មានអាចត្រូវបានប្រើនៅក្នុងឃុំទាំងអស់ក្នុងអំឡុងពេលច្រើនឆ្នាំ ខណៈពេលដែលព័ត៌មានរៀបចំតាមតម្រូវការអាចបិទបន្ថែមពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពជូនដល់ពលរដ្ឋ។ នៅពេលចងក្រងហើយ ផ្ទាំងព័ត៌មាននឹងផ្តល់នូវរូបភាពមួយអំពីអ្វីដែលរាជរដ្ឋាភិបាលនិយាយថាខ្លួននឹងធ្វើ (និយាម និង ចំណុចដៅ) អ្វីដែលខ្លួនពិតជាបានធ្វើ (សូចនាករស្នាដៃការងារ) និង ជាមួយមូលនិធិអ្វី (ថវិកា និង ចំណាយ)។

ក្រៅពីផ្ទាំងព័ត៌មាន កូនសៀវភៅមួយត្រូវបានរៀបចំ ដោយផ្តល់ព័ត៌មានសាវតារអំពីសិទ្ធិ និង និយាម។ កូនសៀវភៅនេះ អាចប្រើបានក្នុងកិច្ចប្រជុំរួមគ្នា។

- *ប្រព័ន្ធមូលដ្ឋានទិន្នន័យមួយ* ត្រូវបានអភិវឌ្ឍដើម្បីប្រមូលព័ត៌មានអំពីស្នាដៃការងារ ថវិកា និង ចំណាយរបស់ឃុំ មណ្ឌលសុខភាព និង សាលាបឋមសិក្សាពាក់ព័ន្ធទាំងអស់។
- *ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាព* អំពីទស្សនាទាននៃគណនេយ្យភាពសង្គម ការប្រើឧបករណ៍ ការប្រើប្រព័ន្ធមូលដ្ឋានទិន្នន័យ ការសម្របសម្រួលកិច្ចប្រជុំ និង ការវាយតម្លៃស្នាដៃការងាររបស់អ្នកផ្តល់សេវាមូលដ្ឋានជាមួយប័ណ្ណដាក់ពិន្ទុរបស់ពលរដ្ឋ និង ស្វ័យវង្វាយតម្លៃ ត្រូវបានទទួលបន្ទុកដោយអង្គការមិនមែនរដ្ឋាភិបាល និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- នៅត្រីមាសចុងក្រោយនៃឆ្នាំ of ២០១៤ ការអនុវត្តសាកល្បងមួយត្រូវបានធ្វើនក្នុងឃុំចំនួន ៣២ ក្នុងស្រុកចំនួន ២២។ សកម្មភាពដែលបានធ្វើ រួមមាន: ការជំរុញការយល់ដឹង ការបណ្តុះបណ្តាលមន្ត្រីនិងបុគ្គលិកស្រុកនិងឃុំ និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិល ការប្រមូលនិងការចែករំលែកព័ត៌មានស្តីពីសិទ្ធិ ថវិកា និង ស្នាដៃការងារ ការត្រួតពិនិត្យតាមដានដោយពលរដ្ឋ កិច្ចប្រជុំរួគ្នា និង ការបង្កើងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា។

## សង្គមស៊ីវិល

សង្គមស៊ីវិលមានតួនាទីដ៏សំខាន់មួយដែលត្រូវបំពេញក្នុងការអនុវត្តគណនេយ្យភាពសង្គម។ នៅក្នុងផែនការសម្រាប់ការអនុវត្ត អង្គការសង្គមស៊ីវិលត្រូវបានលើកឡើងថាជាអ្នកអនុវត្តនិងដៃគូគន្លឹះរបស់រាជរដ្ឋាភិបាល។ អង្គការសង្គមស៊ីវិល នឹងសេវាអភិវឌ្ឍសមត្ថភាពកាន់តែច្រើនឡើង។ ពួកគេនឹងផ្តល់



# គណនេយ្យភាពសង្គម ក្នុងមួយក្រឡេកភ្នែក

WGPD

Working Group for Partnerships in Decentralization
ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ

**ខិត្តប័ណ្ណព័ត៌មានសម្រាប់សមាជិក**

# ការពិតរហ័សអំពីគណនេយ្យភាពសង្គម

ភាពអង់អាចដល់សហគមន៍ និង ពលរដ្ឋ ដើម្បីចូលរួមក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ ហើយពួកគេនឹងតស៊ូមតិ ចូលរួម តាមដានមើលវឌ្ឍនភាព និង ចូលរួមក្នុងការរៀបចំគោលនយោបាយ។ សង្គមស៊ីវិលនឹងកាន់តែក្លាយជាដៃគូមួយដើម្បីអភិវឌ្ឍន៍។ អង្គការសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាលជាតិ គឺជាអ្នកអនុវត្តចម្បងនៃកម្មវិធីគណនេយ្យភាពសង្គមមួយ ដែលមានមុខមាត់យ៉ាងលេចធ្លោក្នុងដំណាក់កាលនេះ។ ពួកគេត្រូវបានរំពឹងថានឹងរួមចំណែកយ៉ាងសំខាន់ដល់ការជំរុញការយល់ដឹង ការអភិវឌ្ឍសមត្ថភាពរបស់ពលរដ្ឋ និង ការជួយគាំទ្រការត្រួតពិនិត្យតាមដានរបស់ពលរដ្ឋ និង កិច្ចប្រជុំរួមគ្នារវាងក្រុមប្រឹក្សាឃុំ និង ពលរដ្ឋឃុំ ក៏ដូចជា ការកៀរគរការចូលរួមរបស់ពលរដ្ឋចំពោះគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងឋានៈជាអង្គការសង្គមស៊ីវិល តើអ្នកយល់ថាចំណុចណាខ្លះមានលក្ខណៈសមស្របបំផុតចំពោះអ្នក និង អង្គការរបស់អ្នក? សូមចូលទៅកាន់គេហទំព័រ xxx ឬ ទាក់ទងលេខាធិការដ្ឋាននៃក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD) ដើម្បីព័ត៌មានបន្ថែមទៀតអំពីគណនេយ្យភាពសង្គម។

ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ គឺជាសម្ព័ន្ធភាពសង្គមស៊ីវិលមួយដែលជំរុញវិមជ្ឈការនៅកម្ពុជា ដោយយកចិត្តទុកដាក់លើការអភិវឌ្ឍបែបប្រជាធិបតេយ្យ

